- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ជាកិច្ចបច្ឆាមរណៈ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនវរសេនីយ៍ទោ **ថោង រតនា** អត្តលេខ ៥៨១០១ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃព្រហស្បតិ៍១២រោចខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា១ ._**

ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ២រូប នៅខេត្តរតនគិរី ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១- លោក **ហេង សារឿន** | ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៣ ពីអភិបាលនៃគណៈអភិបាលស្រុកវើនសៃ ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលស្រុកតាវែង |
| ២- លោក **សូ វណ្ណធិន** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ពីអភិបាលនៃគណៈអភិបាលស្រុកតាវែង ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលស្រុកវើនសៃ។ |

**មាត្រា២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃព្រហស្បតិ៍ ១២រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦៣ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានដាក់លោក **ស្រី អូន** អត្តលេខ **១៦៨០៣០០០៩០** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ **១** នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន ឱ្យចូលនិវត្តន៍មុនអាយុកំណត់តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី**១ ខែមករា ឆ្នាំ២០២៦**។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២ រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៥៣រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

| | | |
|---|---|---|
| ១-លោក | ឈាង គឹមស៊ិន | អធិការ នៃអគ្គាធិការដ្ឋាន |
| ២-លោក | ជុំ មុំ | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៣-លោក | ឯម សោភ័ណ្ឌរិទ្ធ | អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ |
| ៤-លោក | ម៉ុតសុខ មេសា | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ |

| | | |
|---|---|---|
| ៥-លោក | ទូច ពណ្ណរាយ | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ៦-លោក | ស៊ឹម ហុង | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ៧-លោក | ហេង ណារ៉ុង | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត។ |

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

| | | |
|---|---|---|
| ១-លោក | ប៉ក់ ហឿន | អធិការ នៃអគ្គាធិការដ្ឋាន |
| ២-លោក | អ៊ូ មាន | អនុប្រធានការិយាល័យ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្មបាតុកម្មនៅតាមគ្រប់មុខសញ្ញា |
| ៣-លោក | មាស ដារ៉ា | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង |
| ៤-លោក | សុខ គុណ | នាយករងវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ៥-លោក | អាន ចាន់សង | នាយករងវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ៦-លោក | ប៉ាវ ម៉េងហៀង | នាយករងវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ៧-លោក | ដៀង សារឿប | ប្រធានការិយាល័យ នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ៨-លោក | លឹក ផល្លា | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង |
| ៩-លោក | ចាន់ យុទ្ធា | ប្រធានការិយាល័យ នៃមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន |
| ១០-លោក | សុខ សាវុធ | ប្រធានការិយាល័យ នៃមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន |
| ១១-លោក | ស៊ឹម ម៉ៅ | ប្រធានសាខាខេត្តឧត្តរមានជ័យ នៃបេឡាជាតិសន្តិសុខសង្គម។ |

គ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

| | | |
|---|---|---|
| ១-លោកជំទាវ | អ៊ុច ជាច័ន្ទមល្លិកា | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ២-លោក | ពឹម សុភា | អធិការ នៃអគ្គាធិការដ្ឋាន |
| ៣-លោក | សាម៉េន សុខា | អនុប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ៤-លោក | ជា សុភនណារិទ្ធ | ប្រធានផ្នែក នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ៥-លោក | ខេង សុគន្ធា | អនុប្រធានផ្នែក នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ៦- លោកស្រី | ជា សោភា | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ |
| ៧-លោក | យឹម ច័ន្ទបូរ | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៨-លោក | ស្រេង សុជាតិ | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៩-លោក | ស៊ិន សាម៉េត | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ១០-លោក | គីវ វុទ្ធា | ប្រធានការិយាល័យ នៃអគ្គាធិការដ្ឋាន |
| ១១-លោក | ជ ចំលែក | ប្រធានការិយាល័យ នៃអគ្គាធិការដ្ឋាន |
| ១២-លោក | ស ជួបវាសនា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ១៣-លោក | ឡាច វណ្ណស័ក្តិ | មន្ត្រី នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ១៤-លោក | នួន ស៊ីណា | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ |
| ១៥-លោក | មន្ត រស្មី | នាយករងវិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ |
| ១៦-លោក | សរ កុសល | នាយករងវិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ |

| | | |
|---|---|---|
| ១៧-លោកស្រី | ផាន់ សុភា | អនុប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបន្ទាយមានជ័យ |
| ១៨-លោក | សយ ម៉ានិត | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១៩-លោក | យុន ពិសិដ្ឋារ៉ា | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ២០-លោក | ហុង ប្រកប | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ |
| ២១-លោកស្រី | លាំ សីលា | ប្រធានការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តឧត្តរមានជ័យ |
| ២២-លោក | សួរ សម្បត្តិ | ប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ២៣-លោក | កាន់ ស្រ៊ុន | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង |
| ២៤-លោក | ឈាន សារិទ្ធ | នាយករងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង |
| ២៥-លោក | ហ៊ិន ឡា | នាយករងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង |
| ២៦-លោកស្រី | សាញ់ សុភាព | នាយិការងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង |
| ២៧-លោក | លឹម ស៊ីថង | ប្រធានការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង |
| ២៨-លោកស្រី | យួន សុខា | ប្រធានការិយាល័យ នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ២៩-លោក | នេត សាម៉ន | ប្រធានដេប៉ាតឺម៉ង់ នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ៣០-លោក | ជី គីមហ៊ន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ៣១-លោក | អាន វ៉ាន់ថា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ៣២-លោក | ចិន សុវុន | អនុប្រធានដេប៉ាតឺម៉ង់ នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ៣៣-លោក | ឱន សុធុល | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន |
| ៣៤-លោក | ឈឿន ជំនោ | គ្រូបង្រៀនកម្រិតបឋម នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង |
| ៣៥-លោក | គឹម សុផាណា | គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ។ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 1162
ថ្ងៃទី 02 ខែ 03 ឆ្នាំ 26
ម៉ោង 10h19

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៦៣ សហវ.ប្រក.អមហ

ក្រសួងមហាផ្ទៃ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបែងចែកចំណូលពីការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៥.នស.៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៦២ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ
- បានឃើញប្រកាសអន្តរក្រសួងលេខ.១៦១...... សហវ.ប្រក.អទច ចុះថ្ងៃទី២៥.. ខែកុម្ភៈ ឆ្នាំ២០២៦ ស្តីពីបែបបទ និងនីតិវិធីនៃការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១** .-

ចំណូលពីការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ដែលប្រមូលបានដោយអនុវត្តតាមប្រកាសអន្តរក្រសួងលេខ.១៦១........សហវ.ប្រក.អទច ចុះថ្ងៃទី២៥.. ខែកុម្ភៈ..ឆ្នាំ២០២៦ ស្តីពីបែបបទ និងនីតិវិធីនៃការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវបានបែងចែកទៅតាមអត្រាជាភាគរយធៀបនឹងចំណូលប្រមូលបាន ដូចខាងក្រោម ៖

១- បង់ចូលថវិកាជាតិ ចំនួន ៤០% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់ក្រសួងមហាផ្ទៃ ចំនួន ៥៩% នៃចំណូលប្រមូលបាន

ប្រាក់រង្វាន់នេះ ចែកចេញជាពីរផ្នែក ៖

- បង់ភាគទានចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១០% នៃប្រាក់រង្វាន់
- ប្រើប្រាស់នៅក្រសួងមហាផ្ទៃ ចំនួន ៩០% នៃប្រាក់រង្វាន់

៣- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន ។

**ប្រការ២** .-

អនុញ្ញាតឱ្យក្រសួងមហាផ្ទៃ បុរេប្រទានប្រាក់រង្វាន់សរុបពីចំណូលប្រមូលបាន និងបើកផ្តល់ចំណែកប្រាក់រង្វាន់ជូនដល់អង្គភាពគោលដៅនីមួយៗ ដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣** .-

ជារៀងរាល់ខែ ក្រសួងមហាផ្ទៃ ត្រូវធ្វើការទូទាត់ប្រាក់រង្វាន់ដែលបានបុរេប្រទានប្រចាំខែ ដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤ .-**

ប្រាក់រង្វាន់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រីរាជការ ដែលបំពេញភារកិច្ចផ្ទាល់និងមន្ត្រីផ្សេងៗទៀត ពង្រឹងយន្តការប្រមូលចំណូល និងចំណាយផ្សេងៗតាមការចាំបាច់ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ការឧបត្ថម្ភប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងមហាផ្ទៃ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ការឧបត្ថម្ភប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ៧កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 777
ថ្ងៃទី 12 02 ឆ្នាំ 26
ម៉ោង 8H51

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៦២៤ សហវ.ប្រក

ក្រសួងរ៉ែនិងថាមពល

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការកែសម្រួលកម្រងសេវាសាធារណៈរបស់ក្រសួងរ៉ែនិងថាមពល

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
line.mefcambodia



ទូរស័ព្ទៈ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រម នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៤៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាប័ណ្ណស្វែងរុករកនិងអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ១៩៥ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ០៧ សរណន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលសិលា
- បានឃើញប្រកាសអន្តរក្រសួងលេខ៤៨៩ សហវ.ប្រក.អទច ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរ៉ែនិងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

កម្រងសេវាសាធារណៈដែលជាឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ៤៨៩ សហវ.ប្រក.អទច ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរ៉ែនិងថាមពល ត្រូវបានកែសម្រួល និងជំនួសដោយកម្រងសេវាសាធារណៈថ្មី ដែលជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ២ .-**

ទម្រង់ បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់សេវាសាធារណៈទៅតាមប្រភេទសេវានីមួយៗ ត្រូវអនុវត្ត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

**ប្រការ៣ .-**

ការបែងចែកចំណូលប្រមូលបានពីសេវាសាធារណៈថ្មី ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ត្រូវអនុវត្តតាមការកំណត់នៃប្រកាសអន្តរក្រសួងលេខ៤៩១ សហវ.ប្រក.អទច ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការបែងចែកចំណូលពីសេវាសាធារណៈ និងចំណូលពីការពិន័យរបស់ក្រសួងរ៉ែនិងថាមពល។

**ប្រការ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ១១កើត ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**កែវ_រតនៈ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី ✓
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ១៦៨៤ សហវ.ប្រក.អទច ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២៥ ស្តីពីការកែសម្រួលកម្រងសេវាសាធារណៈរបស់ក្រសួងរ៉ែនិងថាមពល

**កម្រងសេវាសាធារណៈ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងរ៉ែនិងថាមពល**

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | I- **អគ្គនាយកដ្ឋានធនធានរ៉ែ** | | | |
| | ក- ការពិនិត្យ ទទួល និងដំណើរការឯកសារ | | | |
| ១ | ១- ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតបញ្ជាក់ ឬលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ឬពន្យារបន្ត ឬបន្តសុពលភាព ឬកែប្រែ ឬផ្ទេរសិទ្ធិអាជ្ញាបណ្ណធនធានរ៉ែ | ១ ០០០ ០០០ | ១០ថ្ងៃ | |
| | ខ- ការចេញលិខិតអនុញ្ញាត ឬការផ្តល់អាជ្ញាបណ្ណ | | | |
| ២ | ១- អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ សម្រាប់អាជីវកម្មថ្មសំណង់ ទំហំមិនលើសពី ១ហិកតា និងជម្រៅមិនហួសពី ៥ម៉ែត្រ | ១ ០០០ ០០០ | ៣០ថ្ងៃ | ១ឆ្នាំ |
| ៣ | ២- លិខិតអនុញ្ញាតបុរេសនា | ៨ ០០០ ០០០ | ៣០ថ្ងៃ | ៦ខែ |
| ៤ | ៣- អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរុករកថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ១០ ០០០ ០០០ | ៣០ថ្ងៃ | ១ឆ្នាំ |
| ៥ | ៤- អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ដីឥដ្ឋ មានទំហំមិនលើសពី ១០ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា) | ១០ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៦ | ៥- អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល មានទំហំមិនលើសពី ១០ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា) | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៧ | ៦- អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ១ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ |
| ៨ | ៧- អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៩ | ៨- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មតិចជាង ៧នាក់ | ៣ ៦០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១០ | ៩- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មចាប់ពី ៧នាក់ ទៅ ១៤នាក់ | ៧ ២០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១១ | ១០- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មលើសពី ១៤នាក់ | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ១២ | ១១- | អាជ្ញាបណ្ណស្វែងរុករក | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១៣ | ១២- | អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ១ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ |
| ១៤ | ១៣- | អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១៥ | ១៤- | អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ (គិតក្នុងមួយឆ្នាំ) | ១០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២១ឆ្នាំ |
| ១៦ | ១៥- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំមន្ត្រីបច្ចេកទេសចុះពិនិត្យទីតាំងស្នើសុំគោលការណ៍អនុញ្ញាតធ្វើអាជីវកម្មខ្សាច់ | ១ ០០០ ០០០ | ១៥ថ្ងៃ | |
| ១៧ | ១៦- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំមន្ត្រីបច្ចេកទេសចុះពិនិត្យ និងការវាស់វែងនាវាដឹកជញ្ជូនផលិតផលរ៉ែ (គិតក្នុងមួយនាវា) | ១ ០០០ ០០០ | ៧ថ្ងៃ | |
| ១៨ | ១៧- | ពិនិត្យ ទទួល និងដំណើរការលិខិតអនុញ្ញាតបញ្ជាក់ការដឹកជញ្ជូនផលិតផលរ៉ែ (សម្រាប់នាំចេញទៅក្រៅប្រទេស ដោយធ្វើការផ្ទេរពីនាវាដឹកជញ្ជូនក្នុងស្រុកទៅនាវានាំចេញ) | ១ ០០០ ០០០ | ៧ថ្ងៃ | ៤៥ថ្ងៃ |
| ១៩ | ១៨- | ពិនិត្យ ទទួល និងដំណើរការលិខិតអនុញ្ញាតលក់ផលិតផលមាស និងផលិតផលរ៉ែលោហៈមានតម្លៃផ្សេងទៀត ដែលមិនទាន់កែច្នៃនៅទីផ្សារក្នុងស្រុក | ១ ០០០ ០០០ | ៧ថ្ងៃ | ៣០ថ្ងៃ |
| | គ- | ការពន្យារសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ | | | |
| ២០ | ១- | លិខិតអនុញ្ញាតបុរេសនា | ៤ ០០០ ០០០ | ៣០ថ្ងៃ | ៣ខែ |
| ២១ | ២- | អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរុករកថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ១០ ០០០ ០០០ | ៣០ថ្ងៃ | ១ឆ្នាំ |
| ២២ | ៣- | អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ដីឥដ្ឋ មានទំហំមិនលើសពី ១០ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា) | ១០ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ២៣ | ៤- | អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល មានទំហំមិនលើសពី ១០ហិកតា (ក្នុងករណីទំហំលើសពី ១០ហិកតា ត្រូវបង់បន្ថែមនូវទំហំដែលលើស ដោយផ្អែកលើមូលដ្ឋានគិត ៤០០ ០០០រៀល ក្នុង ១ហិកតា) | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ២៤ | ៥- | អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ២៥ | ៦- អាជ្ញាបណ្ណស្វែងរុករក | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ២៦ | ៧- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ១ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ |
| ២៧ | ៨- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ២៨ | ៩- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ (គិតក្នុងមួយឆ្នាំ) | ១០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ១០ឆ្នាំ |
| | **ឃ- ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណធនធានរ៉ែ** | | | |
| ២៩ | ១- អាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរុករកថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ១០ ០០០ ០០០ | ៣០ថ្ងៃ | |
| ៣០ | ២- អាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ដីឥដ្ឋ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៣១ | ៣- អាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ៥០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៣២ | ៤- អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ៥០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៣៣ | ៥- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មតិចជាង ៧នាក់ | ២ ៥០០ ០០០ | ៤៥ថ្ងៃ | |
| ៣៤ | ៦- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មចាប់ពី ៧នាក់ ទៅ ១៤នាក់ | ៥ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៣៥ | ៧- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មលើសពី ១៤នាក់ | ៨ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៣៦ | ៨- អាជ្ញាបណ្ណស្វែងរុករក | ១០០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៣៧ | ៩- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម | ១០០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៣៨ | ១០- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ | ២០០ ០០០ ០០០ | ៤៥ថ្ងៃ | |
| | **ង- ការកែប្រែ (ការចេញលិខិតទទួលស្គាល់ការផ្លាស់ប្ដូរសមាសភាពភាគហ៊ុន និងឬការផ្លាស់ប្ដូរអ្នកគ្រប់គ្រងក្រុមហ៊ុន ការកែលម្អ ឬបន្ថែម ឬបន្ថយផ្ទៃដី និងកម្មវត្ថុអាជីវកម្ម) ដែលនាំឱ្យមានការកែប្រែផលប្រយោជន៍ពាក់ព័ន្ធនឹងអាជ្ញាបណ្ណ** | | | |
| ៣៩ | ១- អាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់គោលបំណងអនុវត្តការងារស្វែងរុករកថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល | ៥ ០០០ ០០០ | ៣០ថ្ងៃ | មិនលើស ១ឆ្នាំ |
| ៤០ | ២- អាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មខ្សាច់ ក្រួស អាចម៍ដី ឡាតេរីត ដីឥដ្ឋ | ២ ៥០០ ០០០ | ៣០ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៤១ | ៣- អាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម សម្រាប់ធ្វើអាជីវកម្មថ្មសំណង់ ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ២០ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤២ | ៤- អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយធំ | ២២ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤៣ | ៥- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មតិចជាង ៧នាក់ | ១ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤៤ | ៦- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មចាប់ពី ៧នាក់ ទៅ ១៨នាក់ | ២ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤៥ | ៧- អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ប្រើកម្លាំងពលកម្មលើសពី ១៨នាក់ | ៤ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤៦ | ៨- អាជ្ញាបណ្ណស្វែងរុករក | ៤៥ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤៧ | ៩- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ១ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤៨ | ១០- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយមធ្យម | ៥០ ០០០ ០០០ | ៣០ថ្ងៃ | |
| ៤៩ | ១១- អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយធំ | ១០០ ០០០ ០០០ | ៣០ថ្ងៃ | |
| | **ច- ការចេញលិខិត ឬវិញ្ញាបនបត្រ បញ្ជាក់ផលិតផលរ៉ែ ឬសំណាករ៉ែ សម្រាប់គោលបំណងនាំចេញ នាំចូល និងបញ្ជាក់បរិមាណរំសេវ-គ្រឿងផ្ទុះនិងសារធាតុគីមី ប្រើប្រាស់ក្នុងការដ្ឋានរ៉ែ** | | | |
| ៥០ | ១- ពិនិត្យ និងដំណើរការឯកសារស្នើសុំ លិខិតបញ្ជាក់សំណាករ៉ែ | ៥០០ ០០០ | ៧ថ្ងៃ | ៣០ថ្ងៃ |
| ៥១ | ២- ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែសម្រាប់ថ្មអារ ម្នាងសិលា និងធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ១ ០០០ ០០០ | ៧ថ្ងៃ | ៣០ថ្ងៃ |
| ៥២ | ៣- ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែសម្រាប់ខ្សាច់ ដីល្បាយខ្សាច់ និងធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ១ ០០០ ០០០ | ៧ថ្ងៃ | ៣០ថ្ងៃ |
| ៥៣ | ៤- ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែសម្រាប់រ៉ែលោហៈ អលោហៈ និងធនធានរ៉ែផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល | ១ ០០០ ០០០ | ៧ថ្ងៃ | ៣០ថ្ងៃ |
| ៥៤ | ៥- ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចូលផលិតផលរ៉ែ | ១ ០០០ ០០០ | ១៥ថ្ងៃ | ៣០ថ្ងៃ |
| ៥៥ | ៦- ពិនិត្យ និងដំណើរការឯកសារស្នើសុំលិខិតកំណត់កូតានាំចេញផលិតផលរ៉ែ (គិតក្នុងមួយកូតា) | ១ ០០០ ០០០ | ១៥ថ្ងៃ | ១ឆ្នាំ |
| ៥៦ | ៧- លិខិតបញ្ជាក់បរិមាណរំសេវ គ្រឿងផ្ទុះ សម្រាប់អាជីវកម្មធនធានរ៉ែ | ៥០០ ០០០ | ១៥ថ្ងៃ | ១ឆ្នាំ |
| ៥៧ | ៨- លិខិតបញ្ជាក់សារធាតុគីមី សម្រាប់វិស័យរ៉ែ | ១ ០០០ ០០០ | ១៥ថ្ងៃ | |
| ៥៨ | ៩- ពិនិត្យ និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការនាំចេញផលិតផលរ៉ែសម្រាប់ផលិតផលមាស | ២ ០០០ ០០០ | ៧ថ្ងៃ | ៣០ថ្ងៃ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | II- **អគ្គនាយកដ្ឋានប្រេងកាត** | | | | |
| | II.១- **ផ្នែកអាប់ស្ទ្រីម** | | | | |
| ៥៩ | ១- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំចុះកិច្ចព្រមព្រៀងប្រេងកាត | ១៦ ៤០០ ០០០ | ៤៥ថ្ងៃ | |
| ៦០ | ២- | លិខិតអនុញ្ញាតលើការចរចាកិច្ចព្រមព្រៀងប្រេងកាត | ២០៥ ០០០ ០០០ | ១៨០ថ្ងៃ | |
| ៦១ | ៣- | ការពន្យារបន្តរយៈពេលលើការចរចាកិច្ចព្រមព្រៀងប្រេងកាត | ២០ ៥០០ ០០០ | ៣០ថ្ងៃ | មិនលើស ៦ខែ (អាស្រ័យលើលិខិតអនុញ្ញាត) |
| ៦២ | ៤- | ការពន្យារបន្តសុពលភាពកិច្ចព្រមព្រៀងប្រេងកាត | ៤១០ ០០០ ០០០ | ១៨០ថ្ងៃ | មិនលើស ១៥ឆ្នាំ (អាស្រ័យលើកិច្ចព្រមព្រៀង) |
| ៦៣ | ៥- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតបុរេសនា ចំពោះគម្រោងទ្រង់ទ្រាយតូច | ៤ ១០០ ០០០ | ៣០ថ្ងៃ | ១ឆ្នាំ |
| ៦៤ | ៦- | ការពន្យារបន្តសុពលភាពលិខិតអនុញ្ញាតបុរេសនា ចំពោះគម្រោងទ្រង់ទ្រាយតូច | ២ ០៥០ ០០០ | ៣០ថ្ងៃ | ៦ខែ |
| ៦៥ | ៧- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតលើការចរចាកិច្ចព្រមព្រៀងបុរេសនា | ១០២ ៥០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ |
| ៦៦ | ៨- | ការពន្យារបន្តរយៈពេលលើការចរចាកិច្ចព្រមព្រៀងបុរេសនា | ២០ ៥០០ ០០០ | ៣០ថ្ងៃ | ៦ខែ |
| ៦៧ | ៩- | ការពន្យារបន្តសុពលភាពកិច្ចព្រមព្រៀងបុរេសនា | ២០ ៥០០ ០០០ | ៣០ថ្ងៃ | ២ឆ្នាំ |
| ៦៨ | ១០- | លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្ទេរសិទ្ធិគ្រប់គ្រង ឬការប្តូរអំណាចគ្រប់គ្រងគម្រោងប្រេងកាត ឬការទទួលស្គាល់ការលក់ភាគហ៊ុន ចេញ ឬចូល | ៤១០ ០០០ ០០០ | ៩០ថ្ងៃ | |
| ៦៩ | ១១- | លិខិតអនុញ្ញាតលើលិខិតទទួលស្គាល់ការផ្លាស់ប្តូរប្រតិបត្តិករដែលទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងប្រេងកាត | ២០ ៥០០ ០០០ | ១៥ថ្ងៃ | |
| ៧០ | ១២- | លិខិតអនុញ្ញាតផលិតកម្មប្រេងកាត | ៤១០ ០០០ ០០០ | ១៨០ថ្ងៃ | តាមគម្រោងផលិតកម្ម |
| ៧១ | ១៣- | លិខិតអនុញ្ញាតផលិតកម្ម ដើម្បីអភិវឌ្ឍន៍ទីផ្សារពាណិជ្ជកម្មឧស្ម័ន | ៤១០ ០០០ ០០០ | ១៨០ថ្ងៃ | ៥ឆ្នាំ |
| ៧២ | ១៤- | ការអនុញ្ញាតបង្កើត និងដំណើរការមូលដ្ឋានផ្គត់ផ្គង់ទំនិញ និងសេវាបម្រើឱ្យប្រតិបត្តិការប្រេងកាត | ១០២ ៥០០ ០០០ | ១៨០ថ្ងៃ | ៥ឆ្នាំ |
| ៧៣ | ១៥- | ការបន្តសុពលភាពការអនុញ្ញាតបង្កើត និងដំណើរការមូលដ្ឋានផ្គត់ផ្គង់ទំនិញ និងសេវាបម្រើឱ្យប្រតិបត្តិការប្រេងកាត | ៥១ ២៥០ ០០០ | ៤៥ថ្ងៃ | ៥ឆ្នាំ |
| ៧៤ | ១៦- | លិខិតអនុញ្ញាតចូលដំណាក់កាលទី២ ឬដំណាក់កាលទី៣ នៃរយៈពេលស្វែងរករក | ៤១ ០០០ ០០០ | ៣០ថ្ងៃ | ២ឆ្នាំ |
| ៧៥ | ១៧- | លិខិតអនុញ្ញាតពន្យារពេលបន្ថែម នៃរយៈពេលស្វែងរករក | ៨២ ០០០ ០០០ | ៣០ថ្ងៃ | មិនលើស ៣ឆ្នាំ (អាស្រ័យលើកិច្ចព្រមព្រៀង) |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ៧៦ | ១៨- | លិខិតអនុញ្ញាតកែសម្រួលលើគម្រោងអភិវឌ្ឍប្រេងកាត | ៤១ ០០០ ០០០ | ៤៥ថ្ងៃ | |
| ៧៧ | ១៩- | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាតដែនគោក (គិតក្នុងមួយប្លុក) | ២ ០៥០ ០០០ | ១៤ថ្ងៃ | ១ថ្ងៃ |
| ៧៨ | ២០- | ការអនុញ្ញាតឱ្យពិនិត្យមើលទិន្នន័យប្រេងកាតដែនសមុទ្រ (គិតក្នុងមួយប្លុក) | ៤១ ០០០ ០០០ | ១៤ថ្ងៃ | ១ថ្ងៃ |
| ៧៩ | ២១- | ការលក់កញ្ចប់ទិន្នន័យប្រេងកាតដែនគោក (គិតក្នុងមួយប្លុក) | ២០ ៥០០ ០០០ | ៣០ថ្ងៃ | |
| ៨០ | ២២- | ការលក់កញ្ចប់ទិន្នន័យប្រេងកាតដែនសមុទ្រ (គិតក្នុងមួយប្លុក) | ៤១០ ០០០ ០០០ | ៣០ថ្ងៃ | |
| ៨១ | ២៣- | លិខិតអនុញ្ញាតសម្រាប់បែបបទនាំចេញ នាំចូលសំណាកគំរូប្រេងកាត | ២ ០៥០ ០០០ | ១៥ថ្ងៃ | ៣០ថ្ងៃ |
| ៨២ | ២៤- | ប្រាក់រង្វាន់ចុះហត្ថលេខាកិច្ចព្រមព្រៀងប្រេងកាត (Agreement Signature Bonus) | តាមការព្រមព្រៀង | | |
| ៨៣ | ២៥- | ប្រាក់រង្វាន់នៃការរកឃើញប្រេងកាត ដែលមានលក្ខណៈពាណិជ្ជកម្ម (Commercial Discovery Bonus) | តាមការព្រមព្រៀង | | |
| ៨៤ | ២៦- | ប្រាក់រង្វាន់ផលិតកម្មប្រេងកាត (Production Bonus) | តាមការព្រមព្រៀង | | |
| | II.២- **ផ្នែកដោនស្ទ្រីម** | | | | |
| | ក- កិច្ចព្រមព្រៀងវិនិយោគផ្នែកដោនស្ទ្រីម | | | | |
| ៨៥ | ១- | លិខិតអនុញ្ញាតការចរចាកិច្ចព្រមព្រៀងវិនិយោគផ្នែកដោនស្ទ្រីម | ២០០ ០០០ ០០០ | ៩០ថ្ងៃ | ១ឆ្នាំ |
| ៨៦ | ២- | លិខិតអនុញ្ញាតការពន្យារបន្តរយៈពេលចរចាកិច្ចព្រមព្រៀងវិនិយោគផ្នែកដោនស្ទ្រីម | ៤០ ០០០ ០០០ | ៣០ថ្ងៃ | ៦ខែ |
| | ខ- សកម្មភាពប្រព្រឹត្តកម្ម | | | | |
| ៨៧ | ១- | លិខិតអនុញ្ញាត ឬអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការសិក្សាសមិទ្ធិលទ្ធភាពសាងសង់រោងចក្រប្រព្រឹត្តកម្ម | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ៨៨ | ២- | វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ | ៣០ ០០០ ០០០ | ៩០ថ្ងៃ | ៥ឆ្នាំ |
| ៨៩ | ៣- | វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបតិចជាង ៥លានលីត្រ ក្នុងមួយឆ្នាំ | ៤ ០០០ ០០០ | ៦០ថ្ងៃ | ៥ឆ្នាំ |
| ៩០ | ៤- | ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្ម ចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ | ៣០ ០០០ ០០០ | ៦០ថ្ងៃ | មិនលើស ៤ឆ្នាំ (អាស្រ័យលើអាយុកាលនៃបទគណ្ឌ) |
| ៩១ | ៥- | ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបតិចជាង ៥លានលីត្រ ក្នុងមួយឆ្នាំ | ៤ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ៤ឆ្នាំ (អាស្រ័យលើអាយុកាលនៃបទគណ្ឌ) |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ៩២ | ៦- អាជ្ញាបណ្ណប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ | ៤០០ ០០០ ០០០ | ១៨០ថ្ងៃ | ១០ឆ្នាំ |
| ៩៣ | ៧- ការបន្តសុពលភាពអាជ្ញាបណ្ណប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មសរុបចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ | ២០០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ៩៤ | ៨- ការផ្ទេរសិទ្ធិអាជ្ញាបណ្ណប្រព្រឹត្តកម្ម ដែលមានសមត្ថភាពផលិតកម្មចាប់ពី ៥លានលីត្រឡើងទៅ ក្នុងមួយឆ្នាំ | ២០០ ០០០ ០០០ | ៤៥ថ្ងៃ | |
| | គ- សកម្មភាពសន្និធិ | | | |
| ៩៥ | ១- លិខិតអនុញ្ញាត ឬអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការសិក្សាសមិទ្ធិលទ្ធភាពបង្កើតមណ្ឌលសន្និធិ | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ១៨ខែ |
| | ២- វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់សកម្មភាពសន្និធិ ដែលមានបរិមាណស្តុកសរុប | | | |
| ៩៦ | - ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត (ក្រៅពីប្រេងរំអិលក្នុងកំប៉ុង ឬធុង) ចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ទនៈ (ក្រៅពីឧស្ម័នឥន្ទនៈក្នុងកំប៉ុងឬធុង) ចាប់ពី ១០១គីឡូក្រាម ដល់ ៥០ ០០០ គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ | ១ ០០០ ០០០ | ៦០ថ្ងៃ | ២ឆ្នាំ |
| ៩៧ | - ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ទនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ | ៤ ០០០ ០០០ | ៩០ថ្ងៃ | ៣ឆ្នាំ |
| ៩៨ | - ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ទនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ | ១០ ០០០ ០០០ | ៩០ថ្ងៃ | ៥ឆ្នាំ |
| ៩៩ | - ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ទនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ | ២០ ០០០ ០០០ | ៩០ថ្ងៃ | ៥ឆ្នាំ |
| | ៣- ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសន្និធិ ដែលមានបរិមាណស្តុកសរុប | | | |
| ១០០ | - ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត (ក្រៅពីប្រេងរំអិលក្នុងកំប៉ុង ឬធុង) ចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ទនៈ (ក្រៅពីឧស្ម័នឥន្ទនៈក្នុងកំប៉ុងឬធុង) ចាប់ពី ១០១គីឡូក្រាម ដល់ ៥០ ០០០ គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលចាប់ពី ២០១លីត្រ ដល់ ១៥០ ០០០លីត្រ | ១ ០០០ ០០០ | ៦០ថ្ងៃ | ២ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ១០១ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ | ៤ ០០០ ០០០ | ៦០ថ្ងៃ | មិនលើស ៣ឆ្នាំ |
| ១០២ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ | ១០ ០០០ ០០០ | ៦០ថ្ងៃ | មិនលើស ៣ឆ្នាំ |
| ១០៣ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ | ២០ ០០០ ០០០ | ៦០ថ្ងៃ | មិនលើស ៤ឆ្នាំ |
| | ៤- | អាជ្ញាបណ្ណសន្និធិ ដែលមានបរិមាណស្តុកសរុប | | | |
| ១០៤ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ | ៤ ០០០ ០០០ | ៩០ថ្ងៃ | ១០ឆ្នាំ |
| ១០៥ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ | ២០ ០០០ ០០០ | ៩០ថ្ងៃ | ១០ឆ្នាំ |
| ១០៦ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ | ៨០ ០០០ ០០០ | ៩០ថ្ងៃ | ១០ឆ្នាំ |
| | ៥- | ការបន្តសុពលភាពអាជ្ញាបណ្ណសន្និធិ ដែលមានបរិមាណស្តុកសរុប | | | |
| ១០៧ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ | ៤ ០០០ ០០០ | ៦០ថ្ងៃ | ១០ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ១០៨ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ | ២០ ០០០ ០០០ | ៦០ថ្ងៃ | ១០ឆ្នាំ |
| ១០៩ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ | ៨០ ០០០ ០០០ | ៦០ថ្ងៃ | ១០ឆ្នាំ |
| | ៦- | ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណសន្និធិ ដែលមានបរិមាណស្តុកសរុប | | | |
| ១១០ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០ ០០០គីឡូក្រាម ដល់ ៥០០ ០០០គីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១៥០ ០០០លីត្រ ដល់ ១លានលីត្រ | ២ ០០០ ០០០ | ៤៥ថ្ងៃ | |
| ១១១ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១លានលីត្រ ដល់ ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥០០ ០០០គីឡូក្រាម ដល់ ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១លានលីត្រ ដល់ ១០លានលីត្រ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ១១២ | - | ចំពោះប្រេងកាត ឬផលិតផលប្រេងកាត ឬគីមីប្រេងកាត លើសពី ១០លានលីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ៥លានគីឡូក្រាម ឬសម្រាប់សកម្មភាពសន្និធិរួម សមមូលលើសពី ១០លានលីត្រ | ៤០ ០០០ ០០០ | ៤៥ថ្ងៃ | |
| | ឃ- | សកម្មភាពដឹកជញ្ជូន | | | |
| ១១៣ | ១- | លិខិតអនុញ្ញាត ឬអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការសិក្សាសមិទ្ធិលទ្ធភាពសាងសង់បំពង់បង្ហូរ | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ១១៤ | ២- | វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការដឹកជញ្ជូនតាមបំពង់បង្ហូរ | ២០ ០០០ ០០០ | ៩០ថ្ងៃ | ៥ឆ្នាំ |
| | ៣- | វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក | | | |
| ១១៥ | - | ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រ ដល់ ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាម ដល់ ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក) | ១០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ១១៦ | - | ចំពោះប្រេងឥន្ធនៈ លើសពី ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក) | ២០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១១៧ | ៤- | ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការដឹកជញ្ជូនតាមបំពង់បង្ហូរ | ២០ ០០០ ០០០ | ៦០ថ្ងៃ | ៥ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ៥- | ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ការដឹកជញ្ជូនក្រៅពីបំពង់បង្ហូរដែលមានមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក | | | |
| ១១៨ | - | ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រ ដល់ ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាម ដល់ ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក) | ១០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ១១៩ | - | ចំពោះប្រេងឥន្ធនៈ លើសពី ៣ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ លើសពី ១ ៥០០គីឡូក្រាម (គិតក្នុងមួយមធ្យោបាយផ្ទុក) | ២០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១២០ | ៦- | អាជ្ញាបណ្ណដឹកជញ្ជូនតាមបំពង់បង្ហូរ | ៣០០ ០០០ ០០០ | ១៨០ថ្ងៃ | ១០ឆ្នាំ |
| ១២១ | ៧- | អាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនប្រេងកាត តាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឆៅ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នធម្មជាតិ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១២២ | ៨- | អាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាត តាមផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នឥន្ធនៈចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១២៣ | ៩- | ការបន្តសុពលភាពអាជ្ញាបណ្ណដឹកជញ្ជូនតាមបំពង់បង្ហូរ | ១៥០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១២៤ | ១០- | ការបន្តសុពលភាពអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនប្រេងកាត តាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឆៅ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នធម្មជាតិ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១២៥ | ១១- | ការបន្តសុពលភាពអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាត តាមផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១២៦ | ១២- | ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណដឹកជញ្ជូនតាមបំពង់បង្ហូរ | ១៥០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ១២៧ | ១៣- | ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនប្រេងកាត តាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឆៅ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬចំពោះឧស្ម័នធម្មជាតិ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១២៨ | ១៤- ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ ដែលមានមធ្យោបាយដឹកជញ្ជូនផលិតផលប្រេងកាត តាមផ្លូវដែក ផ្លូវទឹក ដែលមធ្យោបាយដឹកជញ្ជូនមានសមត្ថភាពផ្ទុក ចំពោះប្រេងឥន្ធនៈ ចាប់ពី ២០១លីត្រឡើងក្នុងមួយលើក ឬ ចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ១០១គីឡូក្រាមឡើងក្នុងមួយលើក | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | |
| | ង- សកម្មភាពពាណិជ្ជកម្ម | | | |
| ១២៩ | ១- អាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពនាំចេញ ឬនាំចូលប្រេងកាត ឬផលិតផលប្រេងកាត | ៥០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១៣០ | ២- ការបន្តសុពលភាពអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពនាំចេញ ឬនាំចូលប្រេងកាត ឬផលិតផលប្រេងកាត | ៤០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១៣១ | ៣- ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពនាំចេញ ឬនាំចូលប្រេងកាត ឬផលិតផលប្រេងកាត | ២៥ ០០០ ០០០ | ៤៥ថ្ងៃ | |
| | ៤- ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំគោលការណ៍នាំចូលប្រេងកាត និងឬផលិតផលប្រេងកាត | | | |
| ១៣២ | - មិនលើសពី ៥០០ ០០០តោន | ១ ០០០ ០០០ | ៥ថ្ងៃ | ប្រចាំឆ្នាំ |
| ១៣៣ | - លើសពី ៥០០ ០០០តោន ដល់ ១ ០០០ ០០០តោន | ១ ៥០០ ០០០ | ៥ថ្ងៃ | ប្រចាំឆ្នាំ |
| ១៣៤ | - លើសពី ១ ០០០ ០០០តោន | ២ ០០០ ០០០ | ៥ថ្ងៃ | ប្រចាំឆ្នាំ |
| ១៣៥ | ៥- ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំកែសម្រួលគោលការណ៍នាំចូលប្រេងកាត និងឬផលិតផលប្រេងកាត | ៥០០ ០០០ | ៥ថ្ងៃ | ប្រចាំឆ្នាំ |
| | ៦- ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតនាំចូលប្រេងកាត និងឬផលិតផលប្រេងកាត (គិតក្នុងមួយតោន) | | | |
| ១៣៦ | - ការនាំចូលតាមផ្លូវទឹក | ១ ០០០ | ៥ថ្ងៃ | ៣០ថ្ងៃ |
| ១៣៧ | - ការនាំចូលតាមផ្លូវគោក | ១ ២០០ | ៥ថ្ងៃ | ៣០ថ្ងៃ |
| | ច- សកម្មភាពវេចខ្ចប់ | | | |
| | ១- វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និងឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ | | | |
| ១៣៨ | - ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម | ៣ ០០០ ០០០ | ៦០ថ្ងៃ | ៣ឆ្នាំ |
| ១៣៩ | - ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ៦ ០០០ ០០០ | ៦០ថ្ងៃ | ៥ឆ្នាំ |
| | ២- ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និងឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ | | | |
| ១៤០ | - ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម | ៣ ០០០ ០០០ | ៦០ថ្ងៃ | ២ឆ្នាំ |
| ១៤១ | - ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ៦ ០០០ ០០០ | ៦០ថ្ងៃ | ៣ឆ្នាំ |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ៣- អាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និងឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ | | | |
| ១៤២ | - ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម | ៥ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១៤៣ | - ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| | ៤- ការបន្តសុពលភាពអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និងឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ | | | |
| ១៤៤ | - ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម | ៥ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១៤៥ | - ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ២០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| | ៥- ការផ្ទេរសិទ្ធិអាជ្ញាបណ្ណពាណិជ្ជកម្ម សម្រាប់សកម្មភាពវេចខ្ចប់ផលិតផលប្រេងកាត និងឬឧស្ម័នឥន្ធនៈ ដែលមានសមត្ថភាពវេចខ្ចប់សរុបក្នុងមួយឆ្នាំ | | | |
| ១៤៦ | - ចំពោះប្រេងឥន្ធនៈ តិចជាង ១៥០ ០០០លីត្រ ឬចំពោះឧស្ម័នឥន្ធនៈ តិចជាង ៥០ ០០០គីឡូក្រាម | ២ ៥០០ ០០០ | ៤៥ថ្ងៃ | |
| ១៤៧ | - ចំពោះប្រេងឥន្ធនៈ ចាប់ពី ១៥០ ០០០លីត្រឡើងទៅ ឬចំពោះឧស្ម័នឥន្ធនៈ ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | |
| | **ឆ- សកម្មភាពផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈ** | | | |
| | ១- វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈ តាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ | | | |
| ១៤៨ | - តិចជាង ៥០ ០០០គីឡូក្រាម | ៣ ០០០ ០០០ | ៤៥ថ្ងៃ | ៣ឆ្នាំ |
| ១៤៩ | - ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | ៤ឆ្នាំ |
| | ២- ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់សកម្មភាពផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈ តាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ | | | |
| ១៥០ | - តិចជាង ៥០ ០០០គីឡូក្រាម | ៣ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ១៥១ | - ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ៣ឆ្នាំ |
| | ៣- អាជ្ញាបណ្ណផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ | | | |
| ១៥២ | - តិចជាង ៥០ ០០០គីឡូក្រាម | ១០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១៥៣ | - ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| | ៤- ការបន្តសុពលភាពអាជ្ញាបណ្ណផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ | | | |
| ១៥៤ | - តិចជាង ៥០ ០០០គីឡូក្រាម | ១០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |
| ១៥៥ | - ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | ១០ឆ្នាំ |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ៥- | ការផ្ទេរសិទ្ធិនៃអាជ្ញាបណ្ណផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈតាមបណ្តាញបំពង់បង្ហូរ ដែលមានសមត្ថភាពផ្គត់ផ្គង់ និងចែកចាយសរុបក្នុងមួយឆ្នាំ | | | |
| ១៥៦ | - | តិចជាង ៥០ ០០០គីឡូក្រាម | ៥ ០០០ ០០០ | ៤៥ថ្ងៃ | |
| ១៥៧ | - | ចាប់ពី ៥០ ០០០គីឡូក្រាមឡើងទៅ | ១៥ ០០០ ០០០ | ៤៥ថ្ងៃ | |
| | ជ- | ការពិនិត្យ ការផ្តល់ និងការពន្យារបន្តលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងឥន្ធនៈនិងឧស្ម័នឥន្ធនៈ | | | |
| | ១- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ | | | |
| ១៥៨ | - | មានទូចាក់ ១គ្រឿង | ៥០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៥៩ | - | មានទូចាក់ ២គ្រឿង | ១ ៥០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦០ | - | មានទូចាក់ ចាប់ពី ៣គ្រឿងឡើង | ២ ០០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦១ | ២- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ | ២ ០០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| | ៣- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ | | | |
| ១៦២ | - | មានទូចាក់ ១គ្រឿង | ៥០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦៣ | - | មានទូចាក់ ២គ្រឿង | ១ ៥០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦៤ | - | មានទូចាក់ ចាប់ពី ៣គ្រឿងឡើង | ២ ០០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦៥ | ៤- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព សម្រាប់ស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ | ២ ០០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| | ៥- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតកែសម្រួលស្ថានីយប្រេងឥន្ធនៈ ឬស្ថានីយឧស្ម័នឥន្ធនៈ | | | |
| ១៦៦ | - | មានទូចាក់ ១គ្រឿង | ៥០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦៧ | - | មានទូចាក់ ២គ្រឿង | ១ ៥០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦៨ | - | មានទូចាក់ ចាប់ពី ៣គ្រឿងឡើង | ២ ០០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៦៩ | ៦- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតកែសម្រួលស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ | ២ ០០០ ០០០ | ២៤ថ្ងៃ | ២ឆ្នាំ |
| ១៧០ | ៧- | ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាតផ្ទេរម្ចាស់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ ឬស្ថានីយរួមប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ | ៥០០ ០០០ | ១០ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ឈ- សកម្មភាពពាក់ព័ន្ធផ្នែកដោនស្ទ្រីម | | | |
| ១៧១ | ១- លិខិតអនុញ្ញាតផ្តល់សេវាគូសប្លង់បច្ចេកទេសរៀបចំគ្រឿងបង្គុំទព្វសម្ភារៈដែលបម្រើឱ្យសកម្មភាពផ្នែកដោនស្ទ្រីម | ៣ ០០០ ០០០ | ៣០ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៧២ | ២- លិខិតអនុញ្ញាតផ្គុំទព្វសម្ភារៈបម្រើឱ្យសកម្មភាពផ្នែកដោនស្ទ្រីម | ៣ ០០០ ០០០ | ៣០ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៧៣ | ៣- លិខិតអនុញ្ញាតផ្តល់សេវា ដំឡើង ជួសជុល ឬថែទាំទព្វសម្ភារៈបម្រើឱ្យសកម្មភាពផ្នែកដោនស្ទ្រីម | ៣ ០០០ ០០០ | ៣០ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៧៤ | ៤- លិខិតអនុញ្ញាតផ្តល់សេវាពិសោធន៍ប្រេងកាត ផលិតផលប្រេងកាត ឬទព្វសម្ភារៈបម្រើឱ្យសកម្មភាពផ្នែកដោនស្ទ្រីម | ៣ ០០០ ០០០ | ៦០ថ្ងៃ | អចិន្ត្រៃយ៍ |
| | III- **អគ្គនាយកដ្ឋានថាមពល** | | | |
| | ក- ការអនុញ្ញាតឱ្យសិក្សាគម្រោងក្នុងវិស័យថាមពល (សម្រាប់ការវិនិយោគឯកជន) | | | |
| | ១- លិខិតអនុញ្ញាត ឬអនុស្សរណៈនៃការយោគយល់គ្នា ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនី ដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នឥន្ធនៈ វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាព | | | |
| ១៧៥ | - មិនលើសពី ១០ ០០០គីឡូវ៉ាត់ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ) |
| ១៧៦ | - លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់ | ២០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ) |
| ១៧៧ | - លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់ | ៣០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ) |
| ១៧៨ | - លើសពី ១០០ ០០០គីឡូវ៉ាត់ | ៥០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ) |
| ១៧៩ | ២- លិខិតអនុញ្ញាត ឬអនុស្សរណៈនៃការយោគយល់គ្នា ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី (គិតក្នុងមួយគីឡូម៉ែត្រ) | ២០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំវិនិយោគ) |
| | ខ- ការពន្យារសុពលភាពនៃការអនុញ្ញាតឱ្យសិក្សាគម្រោងក្នុងវិស័យថាមពល (សម្រាប់ការវិនិយោគឯកជន) | | | |
| | ១- លិខិតអនុញ្ញាត ឬអនុស្សរណៈនៃការយោគយល់គ្នា ឱ្យធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាព ឬសមិទ្ធិលទ្ធភាពគម្រោងផលិតកម្មអគ្គិសនី ដោយប្រើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នឥន្ធនៈ វារីអគ្គិសនី ជីវម៉ាស់ ពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត ដែលមានអានុភាព | | | |
| ១៨០ | - មិនលើសពី ១០ ០០០គីឡូវ៉ាត់ | ៥ ០០០ ០០០ | ១៥ថ្ងៃ | មិនលើស ១២ខែ |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៨១ | - លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់ | ១០ ០០០ ០០០ | ១៥ថ្ងៃ | មិនលើស ២៤ខែ |
| ១៨២ | - លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់ | ១៥ ០០០ ០០០ | ១៥ថ្ងៃ | មិនលើស ៣៦ខែ |
| ១៨៣ | - លើសពី ១០០ ០០០គីឡូវ៉ាត់ | ២៥ ០០០ ០០០ | ១៥ថ្ងៃ | មិនលើស ៣៦ខែ |
| ១៨៤ | ២- លិខិតអនុញ្ញាត ឬអនុស្សរណៈនៃការយោគយល់គ្នា ឱ្យធ្វើការសិក្សាបុរេលទ្ធភាព ឬលទ្ធភាពគម្រោងខ្សែបញ្ជូន និងចែកចាយថាមពលអគ្គិសនី (គិតក្នុងមួយគីឡូម៉ែត្រ) | ១០ ០០០ | ១៥ថ្ងៃ | មិនលើស ១២ខែ |
| | គ- ការអនុញ្ញាតវិនិយោគសម្រាប់ផលិតកម្មអគ្គិសនី (សម្រាប់ការវិនិយោគឯកជន) | | | |
| | ១- ប្រកាសអនុញ្ញាត និងឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងវិនិយោគ សម្រាប់ផលិតកម្មអគ្គិសនី ដែលមានអានុភាព | | | |
| ១៨៥ | - មិនលើសពី ១០ ០០០គីឡូវ៉ាត់ | ២០ ០០០ ០០០ | - ៦០ថ្ងៃ សម្រេចត្រឹមក្រសួង<br>- ២០ថ្ងៃ ក្រោយពីទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាល | ស្របតាមប្រកាស ឬកិច្ចព្រមព្រៀង |
| ១៨៦ | - លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់ | ៤០ ០០០ ០០០ | | |
| ១៨៧ | - លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់ | ៦០ ០០០ ០០០ | | |
| ១៨៨ | - លើសពី ១០០ ០០០គីឡូវ៉ាត់ | ១៥០ ០០០ ០០០ | | |
| | ឃ- ការអនុញ្ញាតវិនិយោគសម្រាប់បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់ការវិនិយោគឯកជន) | | | |
| ១៨៩ | ១- ប្រកាសអនុញ្ញាតវិនិយោគអគ្គិសនី សម្រាប់បណ្តាញអគ្គិសនីតង់ស្យុងទាប និងឬតង់ស្យុងមធ្យម | ១ ០០០ ០០០ | ៤៥ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| | ២- ប្រកាសអនុញ្ញាត និងឬចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងវិនិយោគអគ្គិសនី សម្រាប់បណ្តាញអគ្គិសនី តង់ស្យុងខ្ពស់ | | | |
| ១៩០ | - ១១៥គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ) | ៨០០ ០០០ | - ៦០ថ្ងៃ សម្រេចត្រឹមក្រសួង<br>- ២០ថ្ងៃ ក្រោយពីទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាល | ស្របតាមកិច្ចព្រមព្រៀង |
| ១៩១ | - ២៣០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ០០០ ០០០ | | |
| ១៩២ | - ៥០០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ២០០ ០០០ | | |
| | ង- ការអនុញ្ញាតផ្ទេរសិទ្ធិវិនិយោគសម្រាប់ផលិតកម្ម បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់ការវិនិយោគឯកជន) | | | |
| | ១- ប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគផលិតកម្មថាមពល សម្រាប់ផលិតកម្មអគ្គិសនី ដែលមានអានុភាព | | | |
| ១៩៣ | - មិនលើសពី ១០ ០០០គីឡូវ៉ាត់ | ២០ ០០០ ០០០ | ២០ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១៩៤ | - លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់ | ៤០ ០០០ ០០០ | ២០ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ១៩៥ | - លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់ | ៦០ ០០០ ០០០ | ២០ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ១៩៦ | - លើសពី ១០០ ០០០គីឡូវ៉ាត់ | ១៥០ ០០០ ០០០ | ២០ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ១៩៧ | ២- ប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគខ្សែបញ្ជូនអគ្គិសនី តង់ស្យុងទាប និងឬតង់ស្យុងមធ្យម | ១ ០០០ ០០០ | ២០ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ១៩៨ | ៣- ប្រកាសអនុញ្ញាតឱ្យផ្ទេរសិទ្ធិការវិនិយោគខ្សែបញ្ជូនអគ្គិសនី តង់ស្យុងខ្ពស់ ១១៥គីឡូវ៉ុល ឬ២៣០គីឡូវ៉ុល ឬ៥០០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ០០០ ០០០ | ២០ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| | ច- ការចុះកិច្ចព្រមព្រៀងគាំទ្រការអនុវត្តគម្រោងវិនិយោគសម្រាប់ផលិតកម្ម បណ្តាញបញ្ជូន និងចែកចាយអគ្គិសនី (សម្រាប់ការវិនិយោគឯកជន) | | | |
| | ១- ការចុះកិច្ចព្រមព្រៀងនវកម្ម សម្រាប់គម្រោងវិនិយោគផលិតកម្មអគ្គិសនី ដែលមានអានុភាព | | | |
| ១៩៩ | - មិនលើសពី ១០ ០០០គីឡូវ៉ាត់ | ២០ ០០០ ០០០ | ១៥ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ២០០ | - លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់ | ៤០ ០០០ ០០០ | ១៥ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ២០១ | - លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់ | ៦០ ០០០ ០០០ | ១៥ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ២០២ | - លើសពី ១០០ ០០០គីឡូវ៉ាត់ | ១៥០ ០០០ ០០០ | ១៥ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| | ២- ការចុះកិច្ចព្រមព្រៀងនវកម្ម សម្រាប់គម្រោងវិនិយោគខ្សែបញ្ជូនអគ្គិសនី | | | |
| ២០៣ | - តង់ស្យុងទាប និងឬតង់ស្យុងមធ្យម | ១ ០០០ ០០០ | ១៥ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| ២០៤ | - តង់ស្យុងខ្ពស់ ១១៥គីឡូវ៉ុល ឬ២៣០គីឡូវ៉ុល ឬ៥០០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ០០០ ០០០ | ១៥ថ្ងៃ | ស្របតាមកិច្ចព្រមព្រៀង |
| | ៣- ការអនុញ្ញាតចុះកិច្ចព្រមព្រៀងផ្ទាល់ សម្រាប់គម្រោងវិនិយោគផលិតកម្មអគ្គិសនី ដែលមានអានុភាព | | | |
| ២០៥ | - មិនលើសពី ១០ ០០០គីឡូវ៉ាត់ | ១០ ០០០ ០០០ | ១៥ថ្ងៃ | |
| ២០៦ | - លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់ | ២០ ០០០ ០០០ | ១៥ថ្ងៃ | |
| ២០៧ | - លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់ | ៣០ ០០០ ០០០ | ១៥ថ្ងៃ | |
| ២០៨ | - លើសពី ១០០ ០០០គីឡូវ៉ាត់ | ៧៥ ០០០ ០០០ | ១៥ថ្ងៃ | |
| | ៤- ចុះកិច្ចព្រមព្រៀងផ្ទាល់ សម្រាប់គម្រោងវិនិយោគខ្សែបញ្ជូនអគ្គិសនី | | | |
| ២០៩ | - តង់ស្យុងទាប និងឬតង់ស្យុងមធ្យម | ៥០០ ០០០ | ១៥ថ្ងៃ | |
| ២១០ | - តង់ស្យុងខ្ពស់ ១១៥គីឡូវ៉ុល ឬ២៣០គីឡូវ៉ុល ឬ៥០០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ) | ៥០០ ០០០ | ១៥ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ៥- ការអនុញ្ញាតឱ្យធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងអនុវត្តគម្រោង សម្រាប់គម្រោងវិនិយោគផលិតកម្មអគ្គិសនី ដែលមានអានុភាព | | | |
| ២១១ | - មិនលើសពី ១០ ០០០គីឡូវ៉ាត់ | ២ ០០០ ០០០ | ១៥ថ្ងៃ | |
| ២១២ | - លើសពី ១០ ០០០គីឡូវ៉ាត់ ដល់ ៥០ ០០០គីឡូវ៉ាត់ | ៤ ០០០ ០០០ | ១៥ថ្ងៃ | |
| ២១៣ | - លើសពី ៥០ ០០០គីឡូវ៉ាត់ ដល់ ១០០ ០០០គីឡូវ៉ាត់ | ៦ ០០០ ០០០ | ១៥ថ្ងៃ | |
| ២១៤ | - លើសពី ១០០ ០០០គីឡូវ៉ាត់ | ១៥ ០០០ ០០០ | ១៥ថ្ងៃ | |
| | ៦- ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងអនុវត្តគម្រោង សម្រាប់គម្រោងវិនិយោគខ្សែបញ្ជូនអគ្គិសនី | | | |
| ២១៥ | - តង់ស្យុងទាប និងឬតង់ស្យុងមធ្យម | ១០០ ០០០ | ១៥ថ្ងៃ | |
| ២១៦ | - តង់ស្យុងខ្ពស់ ១១៥គីឡូវ៉ុល ឬ២៣០គីឡូវ៉ុល ឬ៥០០គីឡូវ៉ុល (គិតក្នុងមួយគីឡូម៉ែត្រ) | ១០០ ០០០ | ១៥ថ្ងៃ | |
| | **ឆ- ការផ្តល់លិខិតអនុញ្ញាតនាំចូល និងប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម** | | | |
| ២១៧ | ១- លិខិតអនុញ្ញាតនាំចូលសារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី១ ដល់ទី៥ នៃឯកសារ IAEA No.RS-G-1.9 2005 (គិតក្នុងមួយប្រភព) | ៣ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ២១៨ | ២- លិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី១ ដល់ទី៥ នៃឯកសារ IAEA No.RS-G-1.9 2005 (គិតក្នុងមួយប្រភព) | ៣ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| ២១៩ | ៣- ការបន្តសុពលភាពលិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី១ ដល់ទី៥ នៃឯកសារ IAEA Nc.RS-G-1.9 2005 (គិតក្នុងមួយប្រភព) | ៣ ០០០ ០០០ | ៤៥ថ្ងៃ | ២ឆ្នាំ |
| | **ជ- ការអនុញ្ញាតឱ្យសិក្សា និងវិនិយោគសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិតថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន)** | | | |
| ២២០ | ១- លិខិតអនុញ្ញាតឱ្យធ្វើការសិក្សាប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិតថាមពលចំហាយ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំគម្រោង) |
| ២២១ | ២- ប្រកាសអនុញ្ញាត និងឬចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិតថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន | ៨០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំគម្រោង) |
| ២២២ | ៣- ប្រកាសអនុញ្ញាត និងឬចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការផលិត ថាមពលចំហាយ សម្រាប់ការធ្វើសេវាកម្ម | ៨០ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំគម្រោង) |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ឈ- | ការអនុញ្ញាតឱ្យសិក្សា និងវិនិយោគសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន) | | | |
| ២២៣ | ១- | លិខិតអនុញ្ញាតឱ្យធ្វើការសិក្សាប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ (គិតក្នុងមួយគីឡូម៉ែត្រ) | ៨០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំគម្រោង) |
| ២២៤ | ២- | ប្រកាសអនុញ្ញាត និងឬចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ០០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំគម្រោង) |
| ២២៥ | ៣- | ប្រកាសអនុញ្ញាត និងឬចុះកិច្ចព្រមព្រៀងសាងសង់ប្រព័ន្ធ និងកិច្ចប្រតិបត្តិការចែកចាយថាមពលចំហាយ សម្រាប់ការធ្វើសេវាកម្ម (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ៥០០ ០០០ | ៤៥ថ្ងៃ | មិនលើស ២៤ខែ (អាស្រ័យលើទំហំគម្រោង) |
| | ញ- | ការចេញអាជ្ញាបណ្ណផ្តល់សេវាកម្ម ផលិត និងចែកចាយថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន) | | | |
| ២២៦ | ១- | អាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន | ៥០ ០០០ ០០០ | ៥០ថ្ងៃ | ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ (អាស្រ័យលើទំហំគម្រោង) |
| ២២៧ | ២- | អាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម | ១០០ ០០០ ០០០ | ៥០ថ្ងៃ | ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ (អាស្រ័យលើទំហំគម្រោង) |
| ២២៨ | ៣- | អាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ០០០ ០០០ | ៥០ថ្ងៃ | ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ (អាស្រ័យលើទំហំគម្រោង) |
| ២២៩ | ៤- | អាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ៥០០ ០០០ | ៥០ថ្ងៃ | ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ (អាស្រ័យលើទំហំគម្រោង) |
| | ដ- | ការអនុញ្ញាតផ្ទេរសិទ្ធិ និងឬបន្តអាជ្ញាបណ្ណផ្តល់សេវាកម្ម ផលិត និងចែកចាយថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន) | | | |
| ២៣០ | ១- | ការផ្ទេរសិទ្ធិ និងឬបន្តអាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន | ៣៥ ០០០ ០០០ | ៤៥ថ្ងៃ | |
| ២៣១ | ២- | ការផ្ទេរសិទ្ធិ និងឬបន្តអាជ្ញាបណ្ណសេវាកម្មផលិតថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម | ៧០ ០០០ ០០០ | ៤៥ថ្ងៃ | |
| ២៣២ | ៣- | ការផ្ទេរសិទ្ធិ និងឬបន្តអាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (គិតក្នុងមួយគីឡូម៉ែត្រ) | ៧០០ ០០០ | ៤៥ថ្ងៃ | |
| ២៣៣ | ៤- | ការផ្ទេរសិទ្ធិ និងឬបន្តអាជ្ញាបណ្ណសេវាកម្មចែកចាយថាមពលចំហាយ សម្រាប់ធ្វើសេវាកម្ម (គិតក្នុងមួយគីឡូម៉ែត្រ) | ១ ០០០ ០០០ | ៤៥ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ឋ- ការចុះបញ្ជីអ្នកគ្រប់គ្រងថាមពល សវនកម្មថាមពល អ្នកធ្វើការជំនាញក្នុងប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំឡើង ថែទាំ ជួសជុលប្រព័ន្ធថាមពល និងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល | | | |
| | ឋ.១- ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំចុះបញ្ជី និងផ្តល់វិញ្ញាបនបត្រ | | | |
| ២៣៤ | ១- អ្នកគ្រប់គ្រងថាមពល | ២០០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| ២៣៥ | ២- សវនករថាមពល | ២០០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| | ៣- អ្នកធ្វើការងារជំនាញក្នុងផ្នែកផលិតកម្មអគ្គិសនី ឬផ្នែកប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី ឬផ្នែកប្រព័ន្ធបណ្តាញចែកចាយអគ្គិសនី ឬផ្នែកប្រើប្រាស់អគ្គិសនី និងឬថាមពល | | | |
| ២៣៦ | - កម្មករជំនាញ | ៤០ ០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ២៣៧ | - កម្រិតអ្នកបច្ចេកទេស | ៦០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| ២៣៨ | - កម្រិតវិស្វករ | ៨០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| | ៤- ក្រុមហ៊ុនផ្តល់សេវាកម្មដំឡើង ថែទាំ ជួសជុល កែលម្អផ្នែក | | | |
| ២៣៩ | - ផលិតកម្មអគ្គិសនី | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៤០ | - ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៤១ | - ប្រព័ន្ធបណ្តាញចែកចាយអគ្គិសនី | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៤២ | - ប្រើប្រាស់អគ្គិសនី និងឬថាមពល | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៤៣ | ៥- ក្រុមហ៊ុនផ្តល់សេវាកម្មដំណោះស្រាយថាមពល | ២ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| | ឋ.២- ការបន្តសុពលភាពវិញ្ញាបនបត្រ | | | |
| ២៤៤ | ១- អ្នកគ្រប់គ្រងថាមពល | ១០០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| ២៤៥ | ២- សវនករថាមពល | ១០០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| | ៣- អ្នកធ្វើការងារជំនាញក្នុងផ្នែកផលិតកម្មអគ្គិសនី ឬផ្នែកប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី ឬផ្នែកប្រព័ន្ធបណ្តាញចែកចាយអគ្គិសនី ឬផ្នែកប្រើប្រាស់អគ្គិសនី និងឬថាមពល | | | |
| ២៤៦ | - កម្រិតអ្នកបច្ចេកទេស | ៤០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| ២៤៧ | - កម្រិតវិស្វករ | ៦០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ៤- ក្រុមហ៊ុនផ្តល់សេវាកម្មដំឡើង ថែទាំ ជួសជុល កែលម្អផ្នែក | | | |
| ២៤៨ | - ផលិតកម្មអគ្គិសនី | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៤៩ | - ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៥០ | - ប្រព័ន្ធបណ្តាញចែកចាយអគ្គិសនី | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៥១ | - ប្រើប្រាស់អគ្គិសនី និងឬថាមពល | ១ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ២៥២ | ៥- ក្រុមហ៊ុនផ្តល់សេវាកម្មដំណោះស្រាយថាមពល | ២ ០០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| | ឌ- ការផ្តល់លិខិតអនុញ្ញាត សម្រាប់ផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល | | | |
| ២៥៣ | ១- ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាត ឬបន្តសុពលភាពលិខិតអនុញ្ញាតផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល | ១០០ ០០០ | ១០ថ្ងៃ | |
| ២៥៤ | ២- លិខិតអនុញ្ញាតផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលជូនអ្នកប្រើប្រាស់អគ្គិសនី | ២ ០០០ ០០០ | ២១ថ្ងៃ | ៥ឆ្នាំ |
| ២៥៥ | ៣- បន្តសុពលភាពលិខិតអនុញ្ញាតផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលជូនអ្នកប្រើប្រាស់អគ្គិសនី | ២ ០០០ ០០០ | ២១ថ្ងៃ | ៥ឆ្នាំ |
| | ឍ- ការផ្តល់លិខិតអនុញ្ញាតឱ្យសាងសង់ដំឡើង បង្កើតស្ថានីយបញ្ចូលថាមពល ឬស្ថានីយផ្លាស់ប្តូរអាគុយ សម្រាប់យានយន្តអគ្គិសនី | | | |
| ២៥៦ | ១- ពិនិត្យ ទទួល និងដំណើរការឯកសារស្នើសុំលិខិតអនុញ្ញាត ឬការផ្ទេរសិទ្ធគ្រប់គ្រងអភិវឌ្ឍ និងសាងសង់ ដំឡើង បង្កើតស្ថានីយបញ្ចូលថាមពល ឬស្ថានីយផ្លាស់ប្តូរអាគុយ | ១០០ ០០០ | ១០ថ្ងៃ | |
| ២៥៧ | ២- លិខិតអនុញ្ញាតអភិវឌ្ឍ និងសាងសង់ដំឡើង បង្កើតស្ថានីយបញ្ចូលថាមពល ឬស្ថានីយផ្លាស់ប្តូរអាគុយ | ១ ០០០ ០០០ | ២១ថ្ងៃ | អចិន្ត្រៃយ៍ |
| ២៥៨ | ៣- លិខិតអនុញ្ញាតផ្ទេរសិទ្ធិគ្រប់គ្រងអភិវឌ្ឍ និងសាងសង់ដំឡើង បង្កើតស្ថានីយបញ្ចូលថាមពល ឬស្ថានីយផ្លាស់ប្តូរអាគុយ | ១ ០០០ ០០០ | ២១ថ្ងៃ | អចិន្ត្រៃយ៍ |
| | ណ- ការចេញលិខិតបញ្ជាក់ជូនក្រុមហ៊ុនក្នុងវិស័យរ៉ែ ថាមពល និងប្រេងកាត (តាមការស្នើសុំ) | | | |
| ២៥៩ | ១- ការនាំចូលគ្រឿងចក្រ គ្រឿងម៉ាស៊ីន សម្ភារៈ បរិក្ខារ បម្រើឱ្យការសាងសង់គម្រោងវិនិយោគក្នុងវិស័យរ៉ែ ថាមពល និងប្រេងកាត (គិតក្នុងមួយយថាប្រភេទ) | ៤ ០០០ | ១៤ថ្ងៃ | |
| ២៦០ | ២- និយោជិត និយោជកបរទេស (គិតក្នុងមួយនាក់) | ២០ ០០០ | ៥ថ្ងៃ | |
| ២៦១ | ៣- លិខិតបញ្ជាក់ផ្សេងៗ ដើម្បីស្នើសុំចេញអាជ្ញាបណ្ណផ្សេងៗ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ (គិតក្នុងមួយលិខិត) | ២០០ ០០០ | ៧ថ្ងៃ | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥៥ សហវ.គសស.វ.ន.អចប

# សេចក្តីសម្រេច
# ស្តីពី
# យន្តការតាមដាន និងវាយតម្លៃវិស័យអចលនទ្រព្យនៅកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញប្រកាសលេខ ០០៨ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ
- បានឃើញប្រកាសលេខ ១០៧ សហវ.ប្រក.ន.អ.ប ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

សេចក្តីសម្រេចនេះមានគោលបំណងបង្កើត និងដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃវិស័យអចលនទ្រព្យនៅកម្ពុជា ដែលនឹងចូលរួមលើកកម្ពស់ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌគណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា (គ.ទ.អ.) ដែលមានតួនាទីរៀបចំ ចងក្រងទិន្នន័យ តាមដានវិភាគ វាយតម្លៃស្ថានភាព ហានិភ័យនៃវិស័យ និងលើកឡើងនូវជម្រើសវិធានការគោលនយោបាយ ក្នុងការឆ្លើយតបទៅនឹងហានិភ័យក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ដើម្បីស្នើសុំការសម្រេចពីថ្នាក់ដឹកនាំ។

**ប្រការ២.-**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះអង្គភាពសម្របសម្រួល និងអង្គភាពរាយការណ៍ដែលស្ថិតក្រោមឱវាទគណៈកម្មការអន្តរក្រសួង គ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា។

## ជំពូកទី២

## អង្គភាពសម្របសម្រួល និងតួនាទី និងភារកិច្ច

**ប្រការ៣.-**

លេខាធិការដ្ឋាននៃ "**គណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា (គ.ទ.អ.)**" បំពេញតួនាទីបន្ថែមជាអង្គភាពសម្របសម្រួលក្នុងការអនុវត្តយន្តការតាមដាន និងវាយតម្លៃវិស័យអចលនទ្រព្យនៅកម្ពុជា ដើម្បីគាំទ្រគណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា ក្នុងការតាមដាន ត្រួតពិនិត្យអនុវត្ត និងវាយតម្លៃវិស័យអចលនទ្រព្យ។

**ប្រការ៤.-**

អង្គភាពសម្របសម្រួលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- អភិវឌ្ឍប្រព័ន្ធតាមដាន និងវាយតម្លៃ ដែលរួមបញ្ចូលនូវយន្តការ ការណែនាំ អនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យសូចនាករ និងឯកសារពាក់ព័ន្ធ
- គ្រប់គ្រងប្រតិបត្តិការនៃប្រព័ន្ធតាមដាន និងវាយតម្លៃ និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់

- ប្រមូល និងចងក្រងទិន្នន័យពីអង្គភាពរាយការណ៍ ដូចមានចែងក្នុងប្រការ ៦ នៃសេចក្តីសម្រេចនេះ
- តាមដាន វិភាគ វាយតម្លៃស្ថានភាព និងហានិភ័យនៃវិស័យអចលនទ្រព្យនៅកម្ពុជា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តយន្តការតាមដាន និងវាយតម្លៃវិស័យអចលនទ្រព្យជូន **គ.ឆ.អ.** និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញតួនាទី និងភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ប្រធាន **គ.ឆ.អ.**។

**ប្រការ៥.-**

អង្គភាពសម្របសម្រួលអាចស្នើសុំ **គ.ឆ.អ.** នូវការសម្រេចបន្ថែមក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាអង្គភាពរាយការណ៍ទៅតាមការវិវត្តជាក់ស្តែងនៃការអនុវត្តយន្តការតាមដាន និងវាយតម្លៃវិស័យអចលនទ្រព្យនៅកម្ពុជា និងគោលនយោបាយនានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍនៃវិស័យអចលនទ្រព្យនៅកម្ពុជា។

## ជំពូកទី៣
## អង្គភាពរាយការណ៍ និងតួនាទី និងភារកិច្ច

**ប្រការ៦.-**

ក្រសួង-ស្ថាប័ន ដែលជាសមាជិកនៃ **គ.ឆ.អ.** បំពេញតួនាទីបន្ថែមជាអង្គភាពរាយការណ៍។ អង្គភាពរាយការណ៍មានក្រសួង-ស្ថាប័នដូចខាងក្រោម៖

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងផែនការ និងវិទ្យាស្ថានជាតិស្ថិតិ
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង
- និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ។

**ប្រការ៧.-**

អង្គភាពរាយការណ៍មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ផ្តល់ទិន្នន័យទៅតាមសូចនាករ ដូចមានកំណត់
- ទទួលខុសត្រូវលើគុណភាព និងភាពពេញលេញនៃទិន្នន័យដែលរាយការណ៍ទៅអង្គភាពសម្របសម្រួល
- បំពេញតួនាទី និងភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ប្រធាន **គ.ឆ.អ.**។

**ប្រការ៨.-**

អង្គភាពរាយការណ៍ត្រូវចាត់តាំងជនបង្គោល ដើម្បីសម្របសម្រួល និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការតាមដាន និងវាយតម្លៃ។

ជនបង្គោលនៅតាមអង្គភាពរាយការណ៍ មានតួនាទីគ្រប់គ្រងគណនីអ្នកប្រើប្រាស់ និងពាក្យសម្ងាត់ដែលផ្តល់ដោយអង្គភាពសម្របសម្រួល ដើម្បីចូលប្រើប្រាស់ប្រព័ន្ធ។

ទិន្នន័យដែលជនបង្គោលបានបញ្ចូលក្នុងប្រព័ន្ធត្រូវចាត់ទុកជាទិន្នន័យផ្លូវការ។ ក្នុងករណីអង្គភាពរាយការណ៍មានបំណងកែសម្រួលទិន្នន័យដែលបានបញ្ចូលរួច អង្គភាពរាយការណ៍ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរមកអង្គភាពសម្របសម្រួល ក្នុងរយៈពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីថ្ងៃដែលទិន្នន័យត្រូវបានបញ្ចូលក្នុងប្រព័ន្ធ។

ក្នុងករណី អង្គភាពរាយការណ៍មិនអាចបំពេញភារកិច្ចគ្រប់ជ្រុងជ្រោយ ដូចមានកំណត់ក្នុងប្រការ៧នៃសេចក្តីសម្រេចនេះ អង្គភាពរាយការណ៍ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជូន **គ.ទ.អ.** ដោយបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់។

## ជំពូកទី៤
## ការធ្វើបច្ចុប្បន្នភាពសូចនាករ និងការបញ្ចូលទិន្នន័យ

**ប្រការ៩.-**

អង្គភាពសម្របសម្រួលអាចពិនិត្យ និងស្នើសុំ **គ.ទ.អ.** ដើម្បីធ្វើបច្ចុប្បន្នភាពលើសូចនាករ ទៅតាមភាពចាំបាច់នៃការអនុវត្តយន្តការតាមដាន និងវាយតម្លៃវិស័យអចលនទ្រព្យនៅកម្ពុជា។

**ប្រការ១០.-**

ជនបង្គោលអង្គភាពរាយការណ៍ត្រូវបញ្ចូលទិន្នន័យក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យអចលនទ្រព្យ ទៅតាមវដ្តនៃរបបរាយការណ៍ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១១.-**

ប្រធាន អនុប្រធាន សមាជិក និងលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ដូចប្រការ១១ (ដើម្បីអនុវត្ត)
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៤២ សហវ.សរ.អហ.អគស

## សារាចរណែនាំបន្ថែម
## ស្តីពី
## លក្ខខណ្ឌទូទាត់កិច្ចសន្យាផ្គត់ផ្គង់ដោយអង្គភាពជំនាញស្ថាប័នរដ្ឋដែលមានធានាសុពលភាពសម្រាប់ចំណាយចរន្ត និងកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងប្រតិបត្តិការចំណាយឆ្នាំ២០២៥ និងការរៀបចំរបាយការណ៍អនុវត្តចំណាយឆ្នាំ២០២៥

យោងប្រកាសលេខ៩៩០ សហវ.ប្រក.អរតន ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា សារាចរណែនាំលេខ០១៣សហវ.សរ.អថ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៥ និងដើម្បីជំរុញការទូទាត់កិច្ចប្រតិបត្តិការចំណាយឆ្នាំ២០២៥ សារាចរណែនាំលេខ០១៥ សហវ.សរ.អហក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូលចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៥ និងដើម្បីជំរុញការទូទាត់កិច្ចប្រតិបត្តិការចំណាយឆ្នាំ២០២៥ ក្នុងគោលបំណងធានាដល់ការងារទូទាត់បិទបញ្ជីចំណាយ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយឆ្នាំ២០២៥ ប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំបន្ថែមអំពីនីតិវិធីអនុវត្តដូចខាងក្រោម៖

### ក-អំពីលក្ខខណ្ឌទូទាត់កិច្ចសន្យាផ្គត់ផ្គង់ដោយអង្គភាពជំនាញស្ថាប័នរដ្ឋដែលមានធានាសុពលភាព សម្រាប់ចំណាយចរន្ត

អនុលោមតាមមាត្រា៤៣នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ បានកំណត់ឱ្យអនុវត្តនីតិវិធីចំណាយចរន្ត (ជំពូក៦១) ត្រូវទូទាត់ក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា និងផ្អែកតាមប្រកាសលេខ៩៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ បានកំណត់អំពីការទូទាត់ចំណាយចរន្តនូវទឹកប្រាក់១០០% នៃតម្លៃកិច្ចសន្យា ក្រោយបញ្ចប់ការងារផ្គត់ផ្គង់ទំនិញ និងការងារសាងសង់ជួសជុល និងសេវាកម្មដែលអនុវត្តដោយអង្គភាពរដ្ឋ ដោយមិនមានប្រាក់តម្កល់ធានាសុពលភាពនោះទេ។ កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ៩៩០ សហវ.ប្រក.អរតន ចុះថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា និងសារាចរលេខ០០៦សហវ.សរអលសា ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៥ ស្តីពីការកំណត់លក្ខខណ្ឌទូទាត់ និងរយៈពេលធានាគុណភាពសំណង់ ប៉ុន្តែជាក់ស្តែង នៅមានការរៀបចំលក្ខខណ្ឌកិច្ចសន្យាមួយចំនួន មិនទាន់បានត្រឹមត្រូវនៅឡើយ។ ដើម្បីសម្រួលដល់ការអនុវត្តចំណាយ ស្របតាមមូលដ្ឋានគណនេយ្យថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមណែនាំបន្ថែមដល់គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ដូចខាងក្រោម៖

- អនុញ្ញាតឱ្យទូទាត់អាណាប័ណ្ណដែលបញ្ជូនដល់រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត បានទាន់ពេលក្នុងរយៈពេលបន្ថែមនៃប្រតិបត្តិការចំណាយឆ្នាំ២០២៥ ក្នុងទំហំទឹកប្រាក់១០០% នៃតម្លៃកិច្ចសន្យាសម្រាប់ការអនុវត្តចំណាយចរន្ត ក្រោយបញ្ចប់ការងារផ្គត់ផ្គង់ទំនិញ ការងារសាងសង់ជួសជុល និងសេវាកម្មដែលអនុវត្តដោយអង្គភាពរដ្ឋ ដោយមានកំណត់ហេតុប្រគល់ ទទួល ឬ កំណត់ហេតុវាយតម្លៃលទ្ធផលការងារ ១០០%នៃទំហំការងារដែលមានចែងក្នុងកិច្ចសន្យា
- ចាប់ពីឆ្នាំ២០២៦តទៅ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំលក្ខខណ្ឌកិច្ចសន្យាសម្រាប់ការអនុវត្តចំណាយចរន្តជូនអង្គភាពជំនាញនៃស្ថាប័នរដ្ឋ ស្របតាមអនុលោមតាមសារាចរលេខ០០៦សហវ. សរអលសា ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៥ និងគោលការណ៍និងបទប្បញ្ញត្តិជាធរមាន។

## ខ-អំពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងប្រតិបត្តិការចំណាយឆ្នាំ២០២៥

១-ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រមូលសក្ខីបត្រ ឯកសារពាក់ព័ន្ធផ្សេងៗ និងរៀបចំលិខិតយុត្តិការចំណាយដែលមានកាលបរិច្ឆេទចុងក្រោយត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ឱ្យបានគ្រប់គ្រាន់និងត្រឹមត្រូវ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងត្រូវបញ្ចូលព័ត៌មាននិងទិន្នន័យបង្កើតប្រតិបត្តិការចំណាយ (Voucher) និងអនុម័តក្នុង FMIS រួចបញ្ជូនទៅអ្នកត្រួតពិនិត្យថវិកា យ៉ាងយូរបំផុតត្រឹមវេលាម៉ោង១៧ និង៣០នាទី **ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦។**

២-អ្នកត្រួតពិនិត្យថវិកា ត្រូវពិនិត្យនិងផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់-អាណត្តិនិយតកម្មឆ្នាំ២០២៥ និងប្រតិបត្តិការចំណាយ (Voucher) ក្នុង FMIS រួចបញ្ជូនបន្តទៅរតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមវេលាម៉ោង១៧ និង៣០នាទី **ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦។**

**៣-ក្រោយកាលបរិច្ឆេទកំណត់វេលាម៉ោង១៧ និង៣០នាទី ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦** រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្មឆ្នាំ២០២៥ និងប្រតិបត្តិការចំណាយ (Voucher)។ អាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងប្រតិបត្តិការចំណាយ (Voucher) ក្នុង FMIS ដែលយឺតយ៉ាវ ត្រូវចាត់ទុកជាមោឃៈក្នុងកិច្ចប្រតិបត្តិការចំណាយឆ្នាំ២០២៥។ រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត ត្រូវពិនិត្យនិងទូទាត់អាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងអនុម័ត Posting ប្រតិបត្តិការចំណាយ (Voucher) ក្នុង FMIS **ហូតដល់ត្រឹមវេលាម៉ោង១៧ និង៣០នាទី ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦។** ចំណែកឯ ចំណាយថវិកាដែលត្រូវបើកសាច់ប្រាក់ ត្រូវបន្ត**ហូតដល់ត្រឹមវេលាម៉ោង១៧ និង៣០នាទី ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦។** ទន្ទឹមនេះ ប្រតិបត្តិការនិយតកម្មគណនេយ្យឆ្នាំ២០២៥ ដែលអនុញ្ញាតឱ្យមានប្រតិបត្តិការកែតម្រូវ ប្រតិបត្តិការជម្រះបញ្ជី និងប្រតិបត្តិការផ្សេងៗទៀត ត្រូវបន្តហូតដល់ **ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦** ដោយត្រូវកត់ត្រាលេខនាគណនេយ្យបន្ថែមនៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

## គ-អំពីការរៀបចំរបាយការណ៍សរុបអនុវត្តចំណាយឆ្នាំ២០២៥

១-ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបូកសរុបផ្ទៀងផ្ទាត់តួលេខចំណាយឆ្នាំ២០២៥ **ឱ្យបានមុនថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ ជាកំហិត។** ចាប់ពី**ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦** អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវដំណើការបូកសរុបប្រតិបត្តិការរតនាគារទូទាំងប្រទេសអំពីការអនុវត្តចំណាយឆ្នាំ២០២៥ យ៉ាងយូរត្រឹម**ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៦។**

២-ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំបិទបញ្ជីឆ្នាំ២០២៥ ឱ្យបានតាមកាលកំណត់ខាងលើ ដើម្បីអាចបូកសរុបរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០២៥ បានទាន់ពេល។ ក្នុងករណីក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងអង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្ញើរបាយការណ៍បូកសរុបទូទាត់មិនទាន់ពេលកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងយកតួលេខរបាយការណ៍របស់អគ្គនាយកដ្ឋានរតនាគារជាតិធ្វើជាតួលេខផ្លូវការ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងនាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-គ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
-អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០២៦.០៥៥.ប្រ.ក

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 517
ថ្ងៃទី 03 ខែ 02 ឆ្នាំ 26
ម៉ោង 10ᴴ18

# ប្រកាស
# ស្តីពី
# ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា១៨និងមាត្រា៥៧នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងកំណត់ប្រាក់បម្រុងកាតព្វកិច្ចទាំងប្រាក់រៀល និងរូបិយប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ក្នុងរយៈពេលតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីរួមចំណែកគ្រប់គ្រងសន្ទនីយភាពប្រកបដោយសុវត្ថិភាព និងស្របតាមនយោបាយរូបិយវត្ថុ។

**ប្រការ ២**.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

**ប្រការ ៣.-**

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **រយៈពេលមូលដ្ឋាន** សំដៅដល់ចំនួនថ្ងៃបន្តបន្ទាប់ដែលគ្រឹះស្ថានត្រូវយកប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗជាប្រាក់រៀល និងជារូបិយប័ណ្ណ មកកំណត់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាសម្រាប់តម្កល់នៅក្នុងរយៈពេលតម្កល់។
- **រយៈពេលតម្កល់** សំដៅដល់ចំនួនថ្ងៃបន្តបន្ទាប់ដែលគ្រឹះស្ថានត្រូវរក្សាទុកទ្រព្យសកម្មបម្រុងជាប្រាក់រៀល និងជារូបិយប័ណ្ណ ដើម្បីស្របតាមកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃនិងប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលបានគណនានៅក្នុងរយៈពេលមូលដ្ឋាន។
- **ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាមធ្យម** សំដៅដល់ចំនួនសរុបនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ក្នុងរយៈពេលមូលដ្ឋានចែកនឹង ៤២ សម្រាប់ប្រាក់រៀល និងចំនួនសរុបនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ក្នុងរយៈពេលមូលដ្ឋានចែកនឹង ១៤ សម្រាប់រូបិយប័ណ្ណ។ ផលចែកដែលជាមធ្យមភាគប្រចាំថ្ងៃ ត្រូវប្រើសម្រាប់កំណត់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាក្នុងរយៈពេលតម្កល់។ ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាមធ្យម ត្រូវគណនាដោយឡែកពីគ្នា សម្រាប់ប្រាក់រៀល និងរូបិយប័ណ្ណ ស្របតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។
- **អត្រាប្រាក់បម្រុងកាតព្វកិច្ច** សំដៅដល់អត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជាអនុវត្តចំពោះចំនួនមធ្យមនៃប្រាក់បញ្ញើនិងប្រាក់កម្ចី សម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលត្រូវរក្សាទុកជាមធ្យមក្នុងរយៈពេលតម្កល់។
- **ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់** សំដៅដល់ចំនួនទ្រព្យសកម្មបម្រុងដែលត្រូវរក្សាក្នុងរយៈពេលតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីកំណត់ទ្រព្យសកម្មបម្រុងអប្បបរមាជាមធ្យមដែលត្រូវតម្កល់។
- **ទ្រព្យសកម្មបម្រុងអប្បបរមាជាមធ្យមដែលត្រូវតម្កល់** សំដៅដល់ចំនួនប្រាក់បម្រុងដែលត្រូវរក្សាទុកក្នុងទម្រង់ជាទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ស្របតាមការកំណត់ក្នុងប្រកាសនេះ។ ចំនួនទ្រព្យសកម្មបម្រុងអប្បបរមាជាមធ្យមដែលត្រូវតម្កល់ជាប្រាក់រៀល ត្រូវបានគណនាដោយបូកចំនួនទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេលតម្កល់ ៤២ ថ្ងៃប្រតិទិន ចែកនឹង ៤២។ ចំណែកឯចំនួនទ្រព្យសកម្មបម្រុងអប្បបរមាជាមធ្យមដែលត្រូវតម្កល់ជារូបិយប័ណ្ណត្រូវបានគណនាដោយបូកចំនួនទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃប្រតិទិន ចែកនឹង ១៤។ ទ្រព្យសកម្មបម្រុងអប្បបរមាជាមធ្យមដែលត្រូវតម្កល់ ត្រូវបានគណនាដោយឡែកពីគ្នា ចំពោះប្រាក់រៀល និងរូបិយប័ណ្ណផ្សេងៗ ស្របតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។
- **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** សំដៅដល់ការកំណត់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀលចំនួនយ៉ាងតិច ០% និងជារូបិយប័ណ្ណផ្សេងៗចំនួនយ៉ាងតិច ៨០% ដែលត្រូវតម្កល់ជារៀងរាល់ថ្ងៃ ក្នុងរយៈពេលតម្កល់នៅក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចរបស់គ្រឹះស្ថាននីមួយៗដែលមាននៅធនាគារជាតិនៃកម្ពុជា។

- **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា** សំដៅដល់ផលគុណរវាងអត្រាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមួយប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាមធ្យម។ ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាត្រូវគណនាមុនរយៈពេលត្រូវតម្កល់ ហើយត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាទៅតាមកាលកំណត់។ ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាត្រូវគណនាសាជាថ្មី និងដោយឡែកពីគ្នារៀងរាល់ ៤២ ថ្ងៃប្រតិទិន សម្រាប់ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល និង ១៤ ថ្ងៃប្រតិទិន សម្រាប់ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារូបិយប័ណ្ណ។

## ជំពូកទី ២
## ប្រាក់បម្រុងកាតព្វកិច្ច

**ប្រការ ៤**.-

ប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍អនុវត្តនយោបាយរូបិយវត្ថុផង និងជាកាតព្វកិច្ចត្រួតពិនិត្យគ្រឹះស្ថានផង។ អត្រាប្រាក់បម្រុងកាតព្វកិច្ចអាចមានការផ្លាស់ប្តូរទៅតាមគោលដៅអនុវត្តនយោបាយរូបិយវត្ថុ និងកាលៈទេសៈសេដ្ឋកិច្ចសកល។ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

ប្រាក់បម្រុងកាតព្វកិច្ចត្រូវអនុវត្តលើប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ដែលរួមមាន ប្រាក់បញ្ញើអតិថិជនទាំងនិវាសនជននិងអនិវាសនជន ប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនិវាសនជន និងប្រាក់កម្ចីអនិវាសនជន លើកលែងប្រាក់កម្ចីអនិវាសនជនដែលមានឥណប្រតិទាននៅសល់ច្រើនជាង ៣ ឆ្នាំ និងបំណុលបន្ទាប់បន្សំដែលទទួលស្គាល់ស្របតាមលក្ខខណ្ឌអនុញ្ញាតឱ្យបូកបញ្ចូលក្នុងដើមទុនបទប្បញ្ញត្តិ ឬមូលនិធិផ្ទាល់សុទ្ធ។

**ប្រការ ៥**.-

គ្រឹះស្ថានត្រូវបង្កើត និងអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យសន្ទនីយភាពប្រុងប្រយ័ត្ន និងសមស្របដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានកំណត់ក្នុងប្រកាសនេះ។

## ជំពូកទី ៣
## ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា

**ប្រការ ៦**.-

គ្រឹះស្ថានត្រូវរក្សាទុកជាមធ្យមនូវសមតុល្យគ្រប់គ្រាន់នៃទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា។

**ប្រការ ៧**.-

សាច់ប្រាក់ក្នុងដៃ មិនត្រូវចាត់ទុកជាទ្រព្យសកម្មដែលអាចទទួលយកបាន ដើម្បីតម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាឡើយ។

ទ្រព្យសកម្មដែលអាចទទួលយកបានសម្រាប់បំពេញប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា រួមមាន៖

- ប្រាក់រៀល៖ សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីចរន្ត ក្នុងរយៈពេលតម្កល់ ៤២ ថ្ងៃប្រតិទិន នៅធនាគារជាតិនៃកម្ពុជា និង
- រូបិយប័ណ្ណ៖ សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច ក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃប្រតិទិន នៅធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៤
## រយៈពេលមូលដ្ឋាន និងរយៈពេលតម្កល់

**ប្រការ ៨**.-

ការគណនាប្រាក់បម្រុងកាតព្វកិច្ចផ្អែកលើរយៈពេលពីរផ្សេងគ្នា គឺ "រយៈពេលមូលដ្ឋាន" និង "រយៈពេលតម្កល់"។

**ប្រការ ៩**.-

រយៈពេលមូលដ្ឋាន ជារយៈពេល ៤២ ថ្ងៃប្រតិទិន សម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗជាប្រាក់រៀល និង ១៤ ថ្ងៃប្រតិទិន សម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗជារូបិយប័ណ្ណ ដែលគ្រឹះស្ថានគណនាមធ្យមភាគប្រចាំថ្ងៃ ដើម្បីកំណត់ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗជាមធ្យម និងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ និងប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា សម្រាប់រាយការណ៍មកធនាគារជាតិនៃកម្ពុជា។ ចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលត្រូវរក្សាទុកក្នុងរយៈពេលតម្កល់ ត្រូវគណនាដោយយកប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជាមធ្យមក្នុងរយៈពេលមូលដ្ឋាន គុណនឹងអត្រាប្រាក់បម្រុងកាតព្វកិច្ចជាធរមាន។

**ប្រការ ១០**.-

រយៈពេលតម្កល់ចាប់ផ្ដើមនៅថ្ងៃទីបួន បន្ទាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន។

រយៈពេលតម្កល់មានរយៈពេល ៤២ ថ្ងៃប្រតិទិន សម្រាប់ទ្រព្យសកម្មបម្រុងជាប្រាក់រៀល និង ១៤ ថ្ងៃប្រតិទិន សម្រាប់ទ្រព្យសកម្មបម្រុងជារូបិយប័ណ្ណ ដែលគ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មដែលអាចទទួលយកបាន ស្របតាមកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃនៅគ្រប់ ៤២ ថ្ងៃប្រតិទិន និង ១៤ ថ្ងៃប្រតិទិននៃរយៈពេលមូលដ្ឋានរៀងគ្នា។ លើសពីនេះ គ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មបម្រុងអប្បបរមាជាមធ្យមដែលត្រូវតម្កល់នៅចុងគ្រានៃរយៈពេលតម្កល់ឱ្យស្មើ ឬលើសពីចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល និងរូបិយប័ណ្ណដែលបានគណនាក្នុងរយៈពេលមូលដ្ឋាន។

## ជំពូកទី ៥
## ទ្រព្យសកម្មបម្រុងអប្បបរមាជាមធ្យមដែលត្រូវតម្កល់

**ប្រការ ១១**.-

ការគណនាប្រាក់បម្រុងកាតព្វកិច្ចអាចមានភាពបត់បែន ដោយសារទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ត្រូវបានគិតជាមធ្យមក្នុងរយៈពេលតម្កល់។ ប៉ុន្តែ គ្រឹះស្ថានត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីធានាការប្រតិបត្តិតាមកម្រិតកំណត់អប្បបរមា ស្របតាមប្រការ ១៤ នៃប្រកាសនេះ។

គ្រឹះស្ថានត្រូវចាត់ទុកថាបានប្រតិបត្តិតាមប្រកាសនេះ ប្រសិនបើចំនួនទ្រព្យសកម្មដែលអាចទទួលយកបានជាមធ្យមត្រូវបានរក្សានៅគ្រប់រយៈពេលតម្កល់យ៉ាងតិចបំផុតស្មើ ១០០% នៃចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលបានគណនាដោយផ្អែកលើតួលេខនៅក្នុងរបាយការណ៍រយៈពេលមូលដ្ឋានពីមុនមក។

**ប្រការ ១២**.-

គណនីចរន្ត និងគណនីប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀលរបស់គ្រឹះស្ថានដែលមានសមតុល្យវិជ្ជមាន ត្រូវបានចាត់ទុកជាទ្រព្យសកម្មដែលអាចទទួលយកបាន សម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល។ សមតុល្យនៃគណនីចរន្ត និងគណនីប្រាក់បម្រុងកាតព្វកិច្ចត្រូវ

បូកបញ្ចូលគ្នារាល់ថ្ងៃ នៅទូទាំងរយៈពេលតម្កល់។ ផលចែករវាងចំនួនសរុបនេះជាមួយនឹង ៩២ ត្រូវបាន យកមកប្រៀបធៀបជាមួយចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលបានគណនានៅក្នុងរយៈពេល មូលដ្ឋាន។

**ប្រការ ១៣.-**

សមតុល្យគណនីចរន្តជារូបិយប័ណ្ណមិនត្រូវចាត់ទុកជាទ្រព្យសកម្មដែលអាចទទួលយកបាន សម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារូបិយប័ណ្ណទេ។ សមតុល្យគណនីប្រាក់បម្រុង កាតព្វកិច្ចជារូបិយប័ណ្ណត្រូវបូកបញ្ចូលគ្នារាល់ថ្ងៃ នៅទូទាំងរយៈពេលតម្កល់ រួចចែកជាមួយនឹង ១៤ ដើម្បីយកមកប្រៀបធៀបជាមួយចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារូបិយប័ណ្ណដែលបានគណនា នៅក្នុងរយៈពេលមូលដ្ឋាន។

## ជំពូកទី ៦
## កម្រិតកំណត់អប្បបរមានៃប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ និងឱនភាពប្រាក់បម្រុងកាតព្វកិច្ច

**ប្រការ ១៤.-**

ក្នុងគោលបំណងគណនាប្រាក់បម្រុងកាតព្វកិច្ចក្នុងរយៈពេលតម្កល់ គ្រឹះស្ថានត្រូវរក្សាទុកនូវ ចំនួនសមតុល្យក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណនៅធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល តម្កល់ ១៤ ថ្ងៃប្រតិទិន យ៉ាងតិចបំផុតស្មើនឹងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃដែលស្មើនឹង ៨០% ជា រូបិយប័ណ្ណ នៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលបានកំណត់ក្នុងរយៈពេលមូលដ្ឋាន និងយ៉ាងតិច បំផុតស្មើ ១០០% នៅចុងគ្រានៃរយៈពេលតម្កល់។

ដោយឡែក ទោះបីជាធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគ្រឹះស្ថានរក្សាកម្រិតកំណត់កាតព្វកិច្ច ប្រចាំថ្ងៃចំពោះប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀលយ៉ាងតិច ០% គ្រឹះស្ថានត្រូវគណនាមធ្យមភាគ នៃផលបូកបញ្ចូលគ្នារវាងសមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីចរន្ត ជាប្រាក់រៀលរបស់ គ្រឹះស្ថាននៅធនាគារជាតិនៃកម្ពុជា ដើម្បីរក្សាចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា យ៉ាងតិចបំផុត ស្មើ ១០០% នៅចុងគ្រានៃរយៈពេលតម្កល់។

**ប្រការ ១៥.-**

ការល្មើសនឹងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃស្មើនឹង ៨០% ជារូបិយប័ណ្ណ និងការរក្សាទុក ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមធ្យមមិនគ្រប់គ្រាន់នៅចុងគ្រានៃរយៈពេលតម្កល់ចំពោះប្រាក់ បម្រុងកាតព្វកិច្ចជាប្រាក់រៀល និងជារូបិយប័ណ្ណ ត្រូវចាត់ទុកថាមានឱនភាពប្រាក់បម្រុងកាតព្វកិច្ច នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យ និងវិធានការត្រួតពិនិត្យគ្រឹះស្ថានដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៧
## ការអនុវត្ត និងការរាយការណ៍ចំពោះការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា

**ប្រការ ១៦.-**

គ្រឹះស្ថានត្រូវអនុវត្តការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល និងរូបិយប័ណ្ណ ដូចបង្ហាញនៅក្នុងតារាងណែនាំស្តីពី រយៈពេលមូលដ្ឋាន និងរយៈពេលតម្កល់ដាច់ដោយឡែក។

**ប្រការ ១៧**.-

